# កំណត់ហេតុ

## វេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី ២៨

# ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជា

# សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

# កម្រិត ២

*ថ្ងៃទី ៣ ខែ មិថុនា ឆ្នាំ ២០២១*

*ម៉ោង ២ :០០ ដល់ ៤:៣០ ល្ងាច*

តាមរយៈប្រព័ន្ធអនឡាញ Google Meet



## មាតិកា


១. សេចក្ដីផ្ដើម 3

២. ដំណើរការ និងលទ្ធផល 3

២.១. សមាសភាពអ្នកចូលរួម 3

២.២. មតស្វាគមន៍ និងបើកកម្មវិធី 4

២.៣. មតបើកកម្មវិធី 6

៣. បទបង្ហាញ 7

៣.១.បទបង្ហាញពីធាតុចូល និងអនុសាសន៍ 7

៣.២. បទបង្ហាញស្ដីពីបច្ចេកទេសស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា 8

៤. វេទិកាពិភាក្សា សំណួរ និងចម្លើយ 9

៥. បិទកម្មវិធី 17

៦. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ 17

៥.១.ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ 18

៧. ឧបសម្ព័ន្ធ 19





HYPERLINK "http://wwww.ccc-cambodia.org/"

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

## ១. សេចក្តីផ្តើម

ដើម្បីឆ្លើយតបនឹងតម្រូវការរបស់សហគមន៍អង្គការមិនមែនរដ្ឋាភិបាល និងដើម្បីចូលរួមចំណែកទប់ស្កាត់នៃការរីករាលដាលនៃជម្ងឺកូវីដ ១៩តាមរយៈការអនុវត្តវិធានការណ៍ និងសេចក្តីណែនាំរបស់រាជរដ្ឋាភិបាលកម្ពុជា អង្គការ គ.ស.ក នឹងរៀបចំវេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២៨ តាមប្រព័ន្ធអនឡាញ ( Google Meet) ក្រោមប្រធានបទ "ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២"។

ត្រឹមខែធ្នូ ឆ្នាំ២០២០ អង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា(គ.ស.ក) មានសមាជិកសរុបទាំងអស់ចំនួនប្រហែល ២០០ស្ថាប័ន ទាំងអង្គការក្នុងស្រុក និងអង្គការបរទេស ដែលធ្វើការលើវិស័យអភិវឌ្ឍន៍ផ្សេងៗគ្នា និងជាវេទិកាសមាជិកមួយធំជាងគេបំផុត សម្រាប់អង្គការសង្គមស៊ីវិលនៅក្នុងប្រទេសកម្ពុជា។

## ២. ដំណើរការ និងលទ្ធផល

- កិច្ចស្វាគមន៍ និងជម្រាបអំពីគោលបំណងវេទិការៀនសូត្រដោយ លោក សុខ ណេង អ្នកឯកទេសផ្នែក Do No Harm
- ការធ្វើមតិស្វាគមន៍ពីលោកស្រី ស៊ិន ពុទ្ធារី នាយិកាប្រតិបត្តិនៃអង្គការ គ.ស.ក
- ការធ្វើមតិបើកកម្មវិធីពី លោកស្រី នាង បូនី អគ្គលេខាធិការរងនៃនិយ័តករគណនេយ្យនិងសវនកម្ម
- ការធ្វើបទបង្ហាញស្តីអំពីធាតុចូល និង អនុសាសន៍ពីអង្គការសង្គមស៊ីវិលទៅលើស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២ ដោយលោក ឆាយ គង់ ប្រធានផ្នែកហិរញ្ញវត្ថុនៃអង្គការ iDE
- ការធ្វើបទបង្ហាញអំពីស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២ ដោយកញ្ញា គួយ សេរីវឌ្ឍនា មន្ត្រីបច្ចេកទេសនៃនិយ័តករគណនេយ្យ និងសវនកម្ម
- សំណួរ និង ចម្លើយ ដែលសម្របសម្រួលដោយ លោក យឿង សុធារ៉ា អ្នកប្រឹក្សាផ្នែកច្បាប់នៃអង្គការ គ.ស.ក

## ២.១. សមាសភាពអ្នកចូលរួម

សិក្ខាកាមមកពីអង្គការក្នុងស្រុក និងអង្គការបរទេសដែលជាសមាជិក និងមិនមែនជាសមាជិកនៃអង្គការ គ.ស.ក ចំនួន ១៣៩ នាក់ បានចូលរួមតាមអនឡាញវេទិការៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី ២៨។

## ២.២. មតស្វាគមន៍ និងបើកម្មវធី

### មតិស្វាគមន៍ដោយលោកស្រី ស៊ិន ពុទ្ធារី នាយិកានៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា

ជាបឋមសូមគោរពដល់លោក លោកស្រីអ្នកនាងកញ្ញា ជាពិសេសសូមគោរពលោកស្រី បូនី ដែលជាតំណាងឯកឧត្តម ប៊ូ ថារិន អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម និងមន្ត្រីនៃអគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម បងប្អូនតំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាល និងសមាជិកនៃអង្គការ CCC ទាំងអស់ដែលមានវត្តមានកំពុងចូលរួមនៅក្នុងកម្មវិធីបានចូលរួមវេទិការៀនសូត្រពីចម្ងាយរបស់យើងជាទីគោរព។ តាំងនាមឱ្យក្រុមការងារហិរញ្ញវត្ថុ និងក្រុមការងារពន្ធដាររបស់អង្គការមិនមែនរដ្ឋាភិបាល និងតាំងនាមឱ្យអ្នករៀបចំកម្មវិធី សូមអរគុណនូវការចំណាយពេលវេលារបស់អស់លោក លោកស្រីនៅក្នុងការចូលរួមសិក្ខាសាលាពីចម្ងាយដោយសារតែការរីករាលដាលនៃជម្ងឺកូវីដ ប៉ុន្តែយើងនៅតែអាចប្រព្រឹត្តទៅតាមការគ្រោងទុក។ ដោយយោងទៅតាមស្មារតី និងការលើកកម្ពស់ភាពជាដៃគូរវាងរាជរដ្ឋាភិបាល ជាមួយនិងអង្គការសមាគមមិនមែនរដ្ឋាភិបាល ហើយដោយអនុលោមទៅតាមសេចក្តីជូនដំណឹងលេខ ០៣០ កជគរបស់ក្រុមប្រឹក្សាជាតិគណនេយ្យ នាងខ្ញុំសូមធ្វើការកត់សម្គាល់នូវវឌ្ឍនភាពមួយចំនួនដែលយើងបានធ្វើរួមគ្នា គឺក្រុមការងារហិរញ្ញវត្ថុអង្គការមិនមែនរដ្ឋាភិបាល ជាមួយនឹងក្រុមការងារពន្ធដាររបស់យើងគឺសូមស្វាគមន៍ និងទទួលស្គាល់នូវការខិតខំប្រឹងប្រែងក៏ដូចជាការចូលរួមរបស់ក្រុមប្រឹក្សាជាតិគណនេយ្យដែលលោកតែងតែធ្វើនៅកំណែទម្រង់គោលនយោបាយក៏ដូចជាការអនុវត្ត ច្បាប់ស្តីពីគណនេយ្យនិងសវនកម្មដោយមានការចូលរួមការពិគ្រោះយោបល់ជាមួយអង្គការសង្គមស៊ីវិលរបស់យើងដោយលោកសម្តៅឱ្យមានចីរភាពរយៈពេលវែងឆ្ងាយក៏ដូចជាទទួលយកនូវធាតុចូលរបស់ក្រុមការងារយើងដើម្បីបង្កើននូវប្រសិទ្ធភាពនៅក្នុងការគ្រប់គ្រងកិច្ចការងារតាមរយៈការធ្វើការកែទម្រង់គោលនយោបាយក៏ដូចជាកិច្ចដំណើរការរបស់ប្រព័ន្ធការងារដើម្បីផ្តល់ជូននូវគណនេយ្យកររបស់យើងឱ្យបានប្រសើរដើម្បីធានានូវតម្លាភាព ប្រសិទ្ធិភាព ភាពងាយស្រួល ជាពិសេសគឺមានភាពឆាប់រហ័សទៅតាមបច្ចុប្បន្នភាពនៃប្រព័ន្ធបច្ចេកវិទ្យារបស់យើង។ ការកំណត់សម្គាល់ទី២ ដែលជាស្នាដៃសំខាន់ៗនោះគឺយើងតែងតែមានវត្តមានអញ្ជើញពីខាងក្រុមប្រឹក្សាជាតិគណនេយ្យ(បច្ចុប្បន្នគឺ និយ័តករគណនេយ្យ និងសវនកម្ម) ដែលលោកមិនដែលបោះបង់ទេ ដែលលោកតែងតែផ្តល់នូវការពិគ្រោះយោបល់ដោយអញ្ជើញតំណាងរបស់យើង ក៏ដូចជាអង្គការ គ.ស.ក ក្នុងការចូលរួម ធ្វើការពិភាក្សាយោបល់សម្រាប់ស្តង់ដារគណនេយ្យកម្រិត២នេះ។ កាលពីឆ្នាំ ២០១៨ យើងដឹងហើយថាស្តង់ដារហិរញ្ញវត្ថុសម្រាប់អង្គការមិនរកប្រាក់ចំណេញ កម្រិត១ ត្រូវបានប្រកាសឱ្យអនុវត្តម្តងមកហើយ ប៉ុន្តែដោយឃើញថាអង្គការសង្គមស៊ីវិលមានការស្នើរសុំ ដូច្នេះរដ្ឋមន្ត្រីនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុលោកក៏បានផ្តល់នូវការពន្យារពេល នៅក្នុងការអនុវត្តស្តង់ដារកម្រិត១ កាលពីឆ្នាំ ២០១៨កន្លងមក ដោយមកទល់ពេលនេះសេចក្តីជូនដំណឹងនេះនៅមានសុពលភាពនៅឡើយ។ ដូច្នេះសូមអរគុណនូវការចូលរួមរបស់ក្រុម

ប្រឹក្សាជាតិគណនេយ្យ នៅក្នុងការគាំទ្រការធ្វើការរបស់អង្គការសង្គមស៊ីវិល និងអង្គការមិនរកប្រាក់ចំណេញ។ ជាបន្ទាប់ នាងខ្ញុំសូមកត់សម្គាល់បញ្ហាប្រឈមជាក់លាក់មួយចំនួនគឺយើងបានធ្វើការពិគ្រោះយោបល់សម្រាប់ក្រុមការងារបច្ចេកទេសហិរញ្ញវត្ថុនិងក្រុមការងារបច្ចេកទសផ្នែកពន្ធដារដែលលោកជាតំណាងអង្គការសង្គមស៊ីវិលក្នុងស្រុកក៏ដូចជាអង្គការសង្គមស៊ីវិលបរទេសដែលជាសមាជិករបស់ខ្លួនគឺមានមូលដ្ឋាននៅទីក្រុងភ្នំពេញក៏ដូចជានៅបណ្ដាខេត្តមួយចំនួន លោកមានជាសំណូមពរសំខាន់ៗដែលខ្ញុំសូមធ្វើការរៀបរាប់ខ្លីៗ ៤ចំណុចសំខាន់ៗដែលលោកលើកឡើងមកៈ

**ទី១) សំវិធានធន** (Provision) ការកំណត់អំពីការប៉ាន់ស្មានទៅលើកាតព្វកិច្ចមួយចំនួនដែលអាចវាស់ស្ទង់ជាថវិកាជាការបង្កើនបន្ទុក និងភាពស្មុគស្មាញដល់ការអនុវត្តកាតព្វកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល

**ទី២) ការថយចុះតម្លៃ** (Impairment) ការវាយតម្លៃលើទ្រព្យ (Asset) នៅចុងឆ្នាំ ឬ ការរកតម្លៃទីផ្សាររបស់សន្និធិ (Inventory) និមួយៗ និងការប្រៀបធៀបនឹងតម្លៃរំលោះដល់ថ្ងៃធ្វើរបាយការណ៍ ព្រមទាំងការធៀបគ្នាជាមួយ Itemម្តងមួយៗ ដែលការណ៍នេះបង្កជាការលំបាកច្រើនសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

**ទី៣) ការប្រើប្រាស់វាក្យស័ព្ទ** (Vocabulary) មានវាក្យស័ព្ទមួយចំនួនដែលត្រូវបានប្រើនៅក្នុងស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ មិនមែនជាភាសាដែលយើងប្រើក្នុងការអនុវត្តនៅក្នុងប្រទេសកម្ពុជាយើង

**ទី៤) ស្ថានភាពអន្តរកាលក្នុងការផ្លាស់ប្តូរការអនុវត្តកិច្ចការបច្ចុប្បន្ន** (Transition Requirement) ក្នុងករណីដែលមានតួលេខប្រៀបធៀប (Comparative Figure) នឹងមានការកែសម្រួលតួលេខ ២ ឆ្នាំចុងក្រោយ ។

នេះគឺជាបញ្ហាប្រឈមទាំង៤ ដែលលើកឡើងក្រុមការងារបច្ចេកទេសរបស់យើង។ យើងនៅតែអរគុណចំពោះក្រុមប្រឹក្សាជាតិគណនេយ្យដែលតែងតែទទួលយកសំណូមពររបស់អង្គការសង្គមស៊ីវិលដោយមានការផ្តល់ជូនវគ្គបណ្តុះបណ្តាលដែលមានភាពទៀងទាត់មានកិច្ចប្រជុំជាប្រចាំជាមួយក្រុមប្រឹក្សាជាតិគណនេយ្យជាមួយហ្នឹងអង្គការសង្គមស៊ីវិលរបស់យើង ក៏ដូចជាការដែលយើងបានធ្វើរួមគ្នានៅពេលនេះ នេះជាដំណោះស្រាយមួយនៅក្នុងបញ្ហាបច្ចេកទេសក៏ដូចជាឱកាសសម្រាប់ពួកខ្ញុំស្វែងរកនូវយុទ្ធសាស្ត្រមួយចំនួនរួមគ្នាដើម្បីបន្តបេសកកម្មរបស់យើងឱ្យមានប្រសិទ្ធិភាពទៅមុខទៀតហើយយើងអាចឈានទៅរកភាពជោគជ័យរួមមួយទាំងអស់គ្នា។

ដូច្នេះជាចុងក្រោយនាងខ្ញុំសូមគោរពជូនពរដល់ឯកឧត្តម លោក លោកស្រី អ្នកនាង កញ្ញា ដែលមានវត្តមាននៅទីនេះទាំងអស់នៅក្នុងកម្មវិធីរបស់យើង ក៏ដូចជាសមាជិក សមាជិកា របស់អង្គការគសក ក៏ដូចជាក្រុមការងារបច្ចេកទេសហិរញ្ញវត្ថុ និងក្រុមការងារពន្ធដារ ដែលលោកតែងតែជួយគាំទ្រនូវកិច្ចការងារនេះ។ សូម


HYPERLINK "http://wwww.ccc-cambodia.org/"

#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

ប្រសិទ្ធពរជ័យទាំង៤ប្រការ អាយុ វណ្ណៈ សុខៈ ពលៈ ហើយសូមឱ្យសុខសប្បាយជៀសឆ្ងាយពីជម្ងឺកូវីដទាំងអស់គ្នា។ សូមអរគុណ។

## ២.៣. មតបើកកម្មវធី

### មតិបើកកម្មវិធីដោយលោកស្រី នាង បូនី អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម

ជាបឋមនាងខ្ញុំសូមជំរាបសួរដល់លោកស្រី ពុទ្ធារី នាយិកា CCC ឯកឧត្តម លោកជំទាវ លោក លោកស្រី ដែលមានវត្តមាននៅសិក្ខាសាលានៅថ្ងៃនេះ។ នាងខ្ញុំមានកិត្តិយសជាតំណាងដ៏ខ្ពង់ខ្ពស់របស់ឯកឧត្តម ប៊ូ ថារិន ដោយសារលោកមានភារកិច្ចបន្ទាន់ផ្សេង។ ដូច្នេះពាក់ព័ន្ធនឹងសេចក្តីព្រាងស្តង់ដារគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត២ កន្លងមកយើងធ្លាប់បានពិភាក្សាច្រើនពាក់ព័ន្ធទៅលើអត្ថបទទាក់ទងនឹងស្តង់ដារនេះគឺយើងបានធ្វើការពិភាក្សាចំនួន២លើក កាលពីថ្ងៃ ២៧ ខែ ឧសភា ឆ្នាំ ២០១៩ និងថ្ងៃទី ២៦ ខែសីហា ឆ្នាំ ២០១៩។ កាលពីខែធ្នូ ឆ្នាំ ២០២០ ក៏យើងបានពិភាក្សាលម្អិតជាថ្មីម្តងទៀត នៅពេលដែលខាងក្រុមបច្ចេកទេសរបស់អាជ្ញាធរគណនេយ្យ និងសវនកម្មទទួលបានធាតុចូលមួយចំនួន ពីក្រុមហ៊ុន សវនកម្ម នៅក្នុងប្រទេសកម្ពុជា។ ហើយការពិភាក្សាកាលពីខែធ្នូនេះដែរ ខាងតំណាងអង្គការ CCC បានស្នើរសុំរយៈពេល ៣ខែ ដើម្បីធ្វើការពិភាក្សាជាមួយអ្នកជំនាញដើម្បីផ្តល់ជាមតិយោបល់បន្ថែមជាធាតុចូល ដើម្បីអង្គការអាចអនុវត្តបាននៅពេលខាងមុខ។ ពាក់ព័ន្ធទៅហ្នឹង ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២ គឺរៀបចំឡើងក្នុងគោលបំណងជាជម្រើស ដោយមិនមែនជាកាតព្វកិច្ចទេ(Not Compulsory) ដែលផ្តល់ជូនអង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលលោកចង់អនុវត្តទៅតាមស្តង់ដារគណនេយ្យមូលដ្ឋានបង្គរទៅតាមតម្រូវការរបស់អង្គការក៏ដូចជាភាគីពាក់ព័ន្ធណាមួយ។ ក្រៅពីនេះ ស្តង់ដារគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត២ នេះក៏យើងផ្តោតលើជាជម្រើស មានន័យថាចំពោះអង្គការធំៗមួយចំនួន ដែលគាត់អនុវត្តស្តង់ដារធំឬស្តង់ដារ SME អញ្ចឹងស្តង់ដារទាំង២នេះមានលក្ខណៈស្មុគស្មាញច្រើន ដូច្នេះស្តង់ដារគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត២គឺយើងធ្វើជាលក្ខណៈ Simple ប៉ុន្តែផ្អែកទៅលើមូលដ្ឋានបង្គរ។ ដូច្នេះនៅក្នុងអត្ថបទស្តង់ដារទាំងមូល យើងបែងចែកជា ២ផ្នែកធំៗ គឺផ្នែក A មាន 9 Sections ផ្នែក B គឺទាក់ទងទៅហ្នឹង Transitional Application ដែលដូចដែលបានជម្រាបខាងលើថាស្តង់ដារនេះគឺជាជម្រើស មានន័យថាអង្គការប្រសិនជាលោកចង់អនុវត្តទៅតាមមូលដ្ឋានគណនេយ្យបង្គរ គឺអាច Upgrade from Tier 1 ឬអាចផ្លាស់ប្តូរការអនុវត្តពីស្តង់ដារផ្សេងទៀតដែលយើងហៅថា Full IFF ឬក៏ IFF SME ដូច្នេះនៅក្នុងឧបសម្ព័ន្ធ B គឺយើងបានបែងចែកទៅជា៣ក្រុម មានន័យថាក្រុមទី១ គឺក្រុម NGO ថ្មីដែលគាត់ជ្រើសរើសអនុវត្តតាម Tier 2 ក្រុមទី២ គឺក្រុម NGO ដែលគាត់អនុវត្តតាមស្តង់ដារ IFF SME ក្រុមទី ៣ គឺគាត់កំពុងតែអនុវត្ត Tier 1 ហើយចង់ Upgrade to Tier 2 ដូច្នេះពាក់ព័ន្ធទៅហ្នឹងអត្ថបទស្តង់ដារនេះ មន្ត្រីជំនាញរបស់យើងនឹងបង្ហាញជូន

អំពី ៩ផ្នែកដែលបានលើកពីខាងលើ។ លោកស្រី ពុទ្ធារី ក៏បានលើកឡើងរួចមកហើយថា កន្លងមកគឺយើងមានការពិភាក្សាច្រើនដង ហើយនេះជាលើកទី ៤ ហើយក្រុមការងារក៏បានលើកឡើងជាការបារម្ភ ៤ចំណុចធំៗ ហើយយើងយកចំណុចទាំងនោះមកពិភាក្សានៅក្នុងថ្ងៃនេះបន្ថែម។ ចំពោះផែនការថ្ងៃអនាគត ចំពោះ Tier 2 នេះគឺយើងហ្នឹងគ្រោងឱ្យដាក់អនុវត្តនៅក្នុងចុងឆ្នាំ ២០២១ នេះ ឬដើមឆ្នាំ ២០២២។ ហើយខ្ញុំគិតថា អង្គការ CCC ក៏បានធ្វើការពិភាក្សាជាមួយខាង Audit Firm ទៅលើអត្ថបទស្តង់ដារនេះពីចំណុចដែលអាចអនុវត្តបាន ហ្នឹងចំណុចដែលមិនអាចអនុវត្តបាន ហើយយើងអាចពីភាក្សានៅថ្ងៃនេះ។ ដោយអត្ថបទនេះមានលក្ខណៈបច្ចេកទេសច្រើន ដូច្នេះត្រង់កន្លែងណាដែលនាងខ្ញុំអាចបំភ្លឺបាន នាងខ្ញុំនឹងបំភ្លឺជូន ហើយកន្លែងណាដែលនាងខ្ញុំមិនអាចបកស្រាយបាន នាងខ្ញុំនឹងបំភ្លឺជូននៅពេលក្រោយ។ នាងខ្ញុំក៏សូមអរគុណដល់អង្គការ CCC ដែលបានសហការយ៉ាងជិតស្និទ្ធជជែកពិភាក្សាដើម្បីផ្តល់ជាធាតុចូលដល់អាជ្ញាធរយើងខ្ញុំដើម្បីជាមូលដ្ឋាននៅក្នុងការដាក់ចេញជាបទបញ្ញត្តិចំពោះ ស្តង់ដារដែលពាក់ព័ន្ធ។ នាងខ្ញុំតំណាងឱ្យឯកឧត្តម ប៊ូ ថារិន នាងខ្ញុំសូមជូនពរលោក លោកស្រីដែលមានវត្តមាននៅថ្ងៃនេះ សូមទទួលបាន សុខភាពល្អ ជៀសឆ្ងាយពីជម្ងឺកូវីដ ហើយទទួលបានជោគជ័យគ្រប់ការងារភារកិច្ច។ នាងខ្ញុំសូមបើកអង្គសិក្ខាសាលា ហើយសូមជូនពរអង្គសិក្ខាសាលាទទួលបានផលផ្លែផ្ការតាមការគ្រោងទុក។

## ៣. បទបង្ហាញ

### ៣.១.បទបង្ហាញពីធាតុចូល និងអនុសាសន៍

**លោក ឆាយ គង់ ប្រធានផ្នែកហិរញ្ញវត្ថុ នៃអង្គការ iDE**

បាទដូចដែលអ្វីលោកស្រី ស៊ិន ពុទ្ធារី បានរៀបរាប់ខាងលើ ចំនួន ៤ចំណុច ហើយខ្ញុំសូមបកស្រាយបន្ថែមនូវអ្វីជាការបារម្ភពីសមាគមអង្គការមិនមែនរដ្ឋាភិបាលដែលយើងបានពិភាក្សាគ្នា។ ដោយសារស្តង់ដារគណនេយ្យសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត២ គឺជាស្តង់ដារថ្មីដែលខាងអង្គការសមាគមគាត់ប្រើប្រព័ន្ធផ្សេងៗគ្នា ហើយក៏មិនបានប្រើប្រាស់ស្តង់ដារណាមួយឱ្យដូចគ្នាទាំងអស់។ ដូច្នេះហើយបានពេលមានស្តង់ដារថ្មីដែលទាក់ទងទៅហ្នឹង Accrual Basis នេះគឺយើងមានការព្រួយបារម្ភ ដែលមាន ៤ចំណុចនេះ។ដោយចំណុចទី១ ដែលទាក់ទងទៅហ្នឹង Provision ដោយអង្គការយើងភាគច្រើនគឺពឹងផ្អែកទៅលើថវិការម្ចាស់ជំនួយ ហើយរាល់ការចំណាយគឺធ្វើទៅតាមផែនការជាក់ស្តែង ដូច្នេះមិនមានថវិការណាបម្រុងទុកទេសម្រាប់យើងយកមកធ្វើ Provision ដោយនៅក្នុង A1.3.3 គឺបានចែងអំពីបំណុលដែលមិនជាក់ស្តែងទៅលើពេលវេលា និង Amount ដូចជាការបំរុងទុកទៅលើការជួសជុលកន្លែងធ្វើការ ឬទាក់ទងនិង Lease Agreement នេះគឺជាការបារម្ភមួយដែលខាងអង្គការសមាគមគិតថាពិបាក convince ទៅកាន់ប្រទេសដែលជាម្ចាស់ជំនួយ ដោយគាត់

ទូទាត់ទៅតាមតែអ្វីដែលជាការជាក់ស្តែង។ ចំណុចទី២ ដែលទាក់ទងទៅហ្នឹង Impairment ដែលវាទាក់ទងទៅហ្នឹង Re-evaluation inventory or Asset ដូចដែលយើងបានដឹងហើយថា ស្ថាប័នអង្គការសមាគមគឺជាស្ថាប័នមិនរកប្រាក់ចំណេញ ដូច្នេះទាក់ទងទៅហ្នឹងរឿង inventory ឬ ស្តុកការលក់ ដូចជាមិន applicable ជាមួយអង្គការរបស់យើងសព្វថ្ងៃ ប្រសិនបើចូលគឺចូលទៅជាប្រភេទអង្គការដែលរកប្រាក់កម្រៃមួយទៀតដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ តម្រូវឱ្យចុះបញ្ជីមួយទៀតដែលជាអង្គការរកប្រាក់កម្រៃ។ ដោយអង្គការសមាគម ជាអង្គការមិនរកប្រាក់កម្រៃគឺយើងស្នើសុំឱ្យលុបត្រង់ចំណុចនេះចេញ ពីព្រោះយើងមិនមានស្តុកលក់ដូរទេ។ ហើយចំពោះការវាយតម្លៃទៅលើបំណុលឬទ្រព្យនោះ ប្រសិនបើយើងយកតាម Historical Principle មានន័យថារាល់បំណុលនឹងទ្រព្យគឺយើងផ្អែកទៅលើតម្លៃដើម ដោយមានន័យថាតម្លៃដើមដែលទិញមកប៉ុន្មាន ទោះបីយើងប្រើប៉ុន្មានឆ្នាំនៅក្នុង Balance Sheet គឺក៏វានៅតែបង្ហាញប្រាប់តម្លៃប៉ុណ្ណឹង។ តែប្រសិនជាយើងត្រូវ Revaluate យើងមិនអាចធ្វើបានដូចខាងវិស័យឯកជន ឬវិស័យធុរកិច្ច ខាងអង្គការគឺមិនអាចធ្វើចំណុចនេះបាន។ ចំណុចទី៣ នៅក្នុងការប្រើប្រាស់វាក្យស័ព្ទ នៅក្នុងភាសា Accounting, Superannuation Contributions ដែលមានការពន្យល់ថាត្រូវមានលុយបម្រុងដែលស្ថាប័នមួយៗត្រូវកាត់ទុកដើម្បីបង្ការទុកសម្រាប់បើកជូនទៅបុគ្គលិក វាស្រដៀងនឹងជាបំណុលមួយដែរ ដែលស្រដៀង និងPension Scheme ដូច្នេះបើតាមបរិបទរាជរដ្ឋាភិបាលយើងគឺយើងមាន Pension Scheme ដូច្នេះខាងអង្គការសង្គមស៊ីវិលសំណូមពរឱ្យប្រើប្រាស់ពាក្យដែលមានទៅតាមបរិបទនៅក្នុងប្រទេសកម្ពុជាយើងដែលមានប្រើពាក្យថា Pension Scheme នេះជំនួស Superannuation Contributions នេះដោយហេតុថាគាត់ងាយយល់ជាង ហើយនេះមិនមែនជាបំណុលទេដែលយើងទម្លាប់អនុវត្តមកគឺចាត់ទុកថាចំណាយតែម្តង យើងទូទាត់ពីខាងម្ចាស់ជំនួយតែម្តង។ ហើយទាក់ទងនឹងចំណុចទី៤ Transition Requirement ដែលយើងមាន Comparative Figure នេះ ដោយសារឃើញនៅក្នុងស្តង់ដារនេះគឺបែងចែកជា២ក្រុម ដែលក្រុមមួយគឺ New Entity ដែលមិនតម្រូវឱ្យមានរបាយការណ៍ឆ្នាំមុនទេ ប៉ុន្តែចំពោះក្រុមទី២ គឺមានចែងថាត្រូវតែមាន Comparative ហើយមានក្រុមអង្គការខុសៗគ្នាទៀតដែលអនុវត្តស្តង់ដារផ្សេងៗគ្នា ដូច្នេះអង្គការមិនមែនរដ្ឋាភិបាលសំណូមពរ ឱ្យអនុវត្តតែមួយ ដោយឆ្នាំទី១ មិនបាច់មាន Comparative ដោយសារយើងមានប្រព័ន្ធផ្សេងៗគ្នា ដោយឆ្នាំទី២ ទី៣ ទើបចាប់ផ្តើមមាននេះជាអ្វីដែលយើងបានពិភាក្សា។ ដូច្នេះខ្ញុំសូមមានការចូលរួមត្រឹមប៉ុណ្ណឹង សូមអរគុណ។

## ៣.២. បទបង្ហាញស្តីពីបច្ចេកទេសស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជា

### កញ្ញា គួយ សេរីវឌ្ឍនា មន្ត្រីបច្ចេកទេសនៃ និយ័តករគណនេយ្យ និងសវនកម្ម

នាងខ្ញុំសូមគោរពលោកស្រី នាង បូនី អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម ដែលជាតំណាងដ៏ខ្ពង់ខ្ពស់នៃឯកឧត្តម ប៊ូ ថារិន អគ្គនាយកនៃ និយ័តករគណនេយ្យនិងសវនកម្ម។ លោកស្រី ស៊ិន ពុទ្ធារី

នាយិកានៃអង្គការ គសក បុគ្គលិកនៃអង្គការ គសក រួមទាំងឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលជាអ្នកចូលរួមនៅក្នុងសិក្ខាសាលារៀនសូត្រនេះ។ នាងខ្ញុំសូមអនុញ្ញាតធ្វើបទបង្ហាញអំពីស្តង់ដារគណនេយ្យ សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត២ដែលក្នុងថ្ងៃនេះនាងខ្ញុំសូមលើកឡើងអំពី ជា៣ចំណុច ទី១ គឺ និយាយអំពីស្តង់ដារ ទី២ និយាយអំពី Appendix A ដែលក្នុងនោះនឹងបង្ហាញអំពីព័ត៌មានចាំបាច់ដែលអង្គការឬ អង្គភាពត្រូវធ្វើតាមដែលមានចែងពី Section ទី១ ដល់ទី ៩ ហើយទី៣ ជាតារាងប្រៀបធៀប ពីស្តង់ដារកម្រិត១ និង ស្តង់ដារកម្រិត២។

នាងខ្ញុំសូមអនុញ្ញតចូលដល់ចំណុចទី១ គឺស្តង់ដារ ដែលស្តង់ដារនេះគឺរៀបចំតាមមូលដ្ឋាន គណនេយ្យ បង្គរហើយនៅក្នុងនេះដែរគឺមាន Framework ដែលមាន appendix A ដែលមានព័ត៌មានចាំបាច់ និង appendix B: Transitional Arrangement, Template, and guidance notes ឬក៏សៀវភៅណែនាំ។

នៅក្នុងផ្នែកបន្ទាប់គឺ Section 1 សេចក្តីផ្តើម...

(សូមមេត្តាពិនិត្យមើលតាម បទបង្ហាញដែលបានភ្ជាប់ជូន)


CFRS for NFPEs Tire 2 030521 (1).pdf

## ៤. វេទិកាពិភាក្សា សំណួរ និងចម្លើយ

ខ្ញុំបាទ យឿង សុធារ៉ា ទីប្រឹក្សាផ្នែកច្បាប់នៃអង្គការ គ.ស.ក។ មុននឹងឈានចូលដល់វគ្គសំណួរចម្លើយ ខ្ញុំបាទសូមបន្ថែមចំណុចមួយចំនួនទៀតពីលើ ចំណុចទាំង ៤ ដែលលោក ឆាយ គង់បានលើកឡើងនោះគឺ ទី១ សូមឱ្យនិយ័តករគណនេយ្យ និងសវនកម្ម មេត្តាផ្តល់នូវការគាំទ្រផ្នែកបច្ចេកទេសបន្ថែមទៅដល់ប្រតិបត្តិករ ទោះបីជាការប្រតិបត្តិស្តង់ដារនេះមិនជាកាតព្វកិច្ចតម្រូវឱ្យអង្គការមិនមែនរដ្ឋាភិបាលត្រូវតែធ្វើ ដែលជាជម្រើស តែអង្គការដែលជ្រើសរើសនូវការប្រតិបត្តិនេះប្រហែលជាអាចជួបប្រទះការស្មុគស្មាញ ហើយសមត្ថភាពរបស់គាត់មានកម្រិត ដូច្នេះស្នើសុំឱ្យ និយ័តករគណនេយ្យនិងសវនកម្ម លោកមេត្តាបន្ត និងសហការជួយបណ្តុះបណ្តាលសមត្ថភាព យ៉ាងហោចណាស់ក៏ផ្តល់នូវអ្នកជំនាញរបស់ខ្លួន ដើម្បីជួយមកដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។ ទី២ គឺថាស្នើរសុំឱ្យមានការព្យួរអំពីបទល្មើសពិន័យអន្តរការទៅលើការប្រព្រឹត្តផ្ទុយបទបញ្ញត្តិស្តីពីគណនេយ្យករ និង សវនកម្ម ដោយអនុក្រឹត្យនេះបានចូលជាធរមានបាន ១ឆ្នាំជាងហើយ។ ហើយប្រាកដណាស់នៅពេលណាដែល

ស្តង់ដារនេះដាក់ឱ្យប្រើប្រាស់ អនុក្រឹត្យនេះនឹងចាប់ផ្តើមឱ្យអនុវត្តដែរ ហើយពេលនោះនឹងមានការផាកពិន័យ ប្រសិនបើមានការខ្វះចន្លោះឆកល្វែងនៅក្នុងការអនុវត្តនៅស្តង់ដារណាមួយ ដូច្នេះនៅក្នុងអំឡុងពេលនៃការអនុវត្ត ឧទាហរណ៍ ១២ខែដំបូង ឬក៏១ឆ្នាំ ដំបូងសុំឱ្យ និយ័តករគណនេយ្យនិងសវនកម្ម ព្យួរការអនុវត្តការពិន័យ ត្រឡប់ជាការណែនាំឬក៏ការស្តីបន្ទោស មានន័យថាមុននឹងឈានដល់ការពិន័យគឺមានការយោគយល់ មានការណែនាំដើម្បីឱ្យគាត់អនុវត្តឱ្យបានត្រឹមត្រូវជាងមុន។ ហើយជាចុងក្រោយទោះបីជាមានការផ្លាស់ប្តូរពី ក្រុមប្រឹក្សាជាតិគណនេយ្យមកជា និយ័តករគណនេយ្យនិងសវនកម្មក្តី ក៏នៅតែស្នើសុំនឹងទទូចឱ្យមានការសហការគ្នាបន្តជាមួយនឹងតំណាងអង្គការសង្គមស៊ីវិលតទៅទៀត ដើម្បីធ្វើការងារនេះតទៅទៀត ដើម្បីធ្វើការរួមគ្នាដើម្បីកសាងបណ្តុះបណ្តាលសមត្ថភាពរបស់អង្គការសង្គមស៊ីវិល ហើយនឹងការស្នើសុំការដោះស្រាយបញ្ហាដោះស្រាយប្រឈមនានាដែលកើតឡើងជុំវិញការអនុវត្តស្តង់ដារទាំង ២ នេះ។

ដូច្នេះខ្ញុំសូមអនុញ្ញាតទទួលសំណួរពីសិក្ខាកាមៈ

**សំណួរៈ** - ទាក់ទងទៅនឹង ស្តង់ដារកម្រិត២នេះ ចំពោះរាល់ជំនួយដែលបានពីម្ចាស់ជំនួយទាំងអស់គឺយើងមិនអាចកត់ត្រាជា Income បានទេ។ តើយើងត្រូវកត់ត្រាជា Differ Income ឬក៏យ៉ាងណា?

មួយទៀតនៅក្នុងកម្រិតទី១ យើងមាន Format នៅក្នុងការបំពេញរបាយការណ៍ ដោយកម្រិត២ នៅមិនទាន់ចេញ format តើ format ដូចកម្រិត១ ឬក៏កំពុងតែរៀបរៀងឡើងនៅឡើយទេ?

**ចម្លើយៈ** - ចំពោះសំណួរអំពីការទទួលស្គាល់ចំណូល នៅក្នុងស្តង់ដារកម្រិត២ នេះគឺយើងមាន Section 5 និយាយអំពី Statement of Financial Performance (Income Statement) ដែលយើងមានជាតារាងមួយដែលនិយាយលម្អិតអំពីការទទួលស្គាល់ចំណូល ដូច្នេះនៅក្នុងប្រភេទចំណូលនេះគឺគេបានបែងចែកជា ៤ប្រភេទធំៗ

ទី១ គឺ Donation, Fund raising and other revenue

ទី២ គឺទាក់ទងទៅហ្នឹង Fee

ទី៣ គឺទាក់ទងទៅហ្នឹង Providing goods and services

ទី៤ គឺទាក់ទងទៅហ្នឹង Interest, or evidence from other investment

ដូច្នេះនៅក្នុងតារាងនេះគឺគេបានបង្ហាញទាំងអស់ថា នៅពេលដែលទទួលស្គាល់ចំណូលពី Donor ត្រូវតែទទួលស្គាល់យ៉ាងដូចម្តេចខ្លះផ្អែកទៅលើមូលដ្ឋានគណនេយ្យបង្គរ។

- សំណួរបន្ទាប់ដែលទាក់ទងទៅនឹង Guidance Note and Format ដូចដែលបានជ្រាបខាងលើគឺស្ថិតនៅក្នុង

ដំណាក់កាលពង្រាងនៅឡើយ ហើយយើងនៅក្នុងដំណាក់កាលពិនិត្យ និងបកប្រែជាភាសាខ្មែរ។ ដូច្នេះស្តង់ដារនេះអាចចេញនៅចុងឆ្នាំឬនៅដើមឆ្នាំ ២០២២ យើងនឹងមានការចងក្រងគ្រប់យ៉ាងរួចជាស្រេចដោយមានទាំងស្តង់ដារ ទម្រង់របាយការណ៍ និងសេចក្តីណែនាំទៅជាមួយគ្នា។

**សំណួរៈ** - ខ្ញុំមានសំណួរទាក់ទងនឹងចំណុច Revenue providing goods and services ត្រង់ចំណុចនេះប្រសិនបើអង្គភាពមិនទាន់ចុះបញ្ជីការប្រកបអាជីវកម្មដោយឡែកខាងពន្ធដារ តើវាអាចមានបញ្ហាជាមួយខាងពន្ធដារដែរឬទេ?

ចំណុចមួយទៀតត្រង់ Statement of Financial Position ចំណុច Investment ឧទាហរណ៍ថាអង្គការនេះគាត់មានទ្រព្យសកម្មរបស់គាត់ទាក់ទងនឹងអគារ ហើយហ្នឹងដី ដូច្នេះគាត់ដាក់ចំណែកណាមួយដាក់ជួលទៅឱ្យភាគីមួយទៀតដើម្បីស្វែងរកប្រាក់ចំណូលផ្សេងទៀត តើយើងគួរតែ evaluate ចាត់របៀបដូចម្តេចនៅក្នុង Statement of Financial Performance?

ទាក់ទងទៅការរៀបចំបែប going concern ខ្ញុំសូមឱ្យបងពន្យល់ឱ្យបានក្បោះក្បាយបន្តិច ឧទាហរណ៍អង្គភាពនេះមិនរំពឹងថាគាត់នឹងអាចរៀបចំ Operation របស់គាត់នៅក្នុងមួយឆ្នាំទៀតទេ តើគាត់គួរតែរៀបចំរបៀបណាដែរ?

**ចម្លើយៈ**

ត្រង់កន្លែងនេះខ្ញុំសូមឆ្លើយតែតាមទិដ្ឋភាពផ្នែកគណនេយ្យ ដោយសំណួរនេះលាយបញ្ចូលជាមួយខាងពន្ធដារ។ ដូច្នេះនៅក្នុង Section 5 គេបានបញ្ជាក់អំពីថាតើ content revenue មានអីគេខ្លះ ដូច្នេះខ្ញុំសូមបញ្ជាក់ដូចពីដើមអញ្ចឹងគឺយើងមាន ៤ ហើយការទទួលស្គាល់ចំណូលក៏ទៅតាមរបាយការណ៍ចំណេញខាតនេះដែរ ហើយនៅក្នុង section នេះបានទទួលស្គាល់ចំណូលនេះតើវាយ៉ាងម៉េច។

(ការចូលរួមពីលោក យឿង សុធារ៉ា) ចំពោះអង្គការសមាគមដែលគាត់រកចំណូលមិនមានគោលដៅសុទ្ធសាធហ្នឹង តាមច្បាប់ឬក៏លិខិតបទដ្ឋានគតិយុត្តិដែលចេញមកថ្មីៗលើកចុងក្រោយនេះគឺតម្រូវឱ្យចុះបញ្ជីដាច់ដោយឡែក សម្រាប់ចំណូលមិនបម្រើឱ្យគោលដៅសុទ្ធសាធ ដោយចំណូលទាំងអស់នោះមិនចាំបាច់ចាំដល់ Threshold ដែលចូលជាអ្នកជាប់ពន្ធទាំង៣ប្រភេទនោះទេ។ ឥលូវនេះកំពុងតែស្ថិតនៅក្នុងការពិភាក្សាគ្នាតើការបានប្រាក់ចំណូលបន្តិចបន្តួចឧទាហរណ៍ថាអង្គការនេះគាត់បើកហាងកាហ្វេ ជាកន្លែង ជួល សម្រាប់ឱ្យអង្គការសង្គមស៊ីវិលគ្នាគាត់ ដោយការបម្រើសេវានេះក្នុងមួយឆ្នាំមិនអាចរកកម្រៃរហូតដល់ ៦ម៉ឺនដុល្លារសហរដ្ឋអាមេរិកទេ តើចំណូលប៉ុណ្ណឹងត្រូវតែចុះបញ្ជីដែរឬអត់។ ហើយបើចុះតើចុះរបៀបម៉េច បើវាមិនត្រូវនៅក្នុងការជាប់ពន្ធទាំង៣ប្រភេទនៅក្នុងរបស្វ័យប្រកាសនេះផង? ច្បាប់បានចែងរួចស្រេចចំពោះអ្នកដែលរកផលរបរបានលើសពី

៦២០០០០ ដុល្លារសហរដ្ឋអាមេរិកគឺត្រូវចុះបញ្ជីជាអ្នកជាប់ពន្ធតូច ដោយធ្វើការប្រកាសដោយខ្លួនឯង។ ប៉ុន្តែច្បាប់មិនបាននិយាយអំពីអ្នករកបានទាបជាងនេះតើគាត់ត្រូវប្រកាសរបៀបដូចម្តេចនោះទេ។ ដូច្នេះគាត់មិនមានកាតព្វកិច្ចច្រើនទេលើកលែងតែប្រជាពលរដ្ឋទូទៅដែលចុះបញ្ជីលើអចលនទ្រព្យប្រជាពលរដ្ឋដែលគាត់ទៅប្រកាសពន្ធតែគាត់មិនជាប់ ពន្ធ។ សម្រាប់អង្គការសង្គមស៊ីវិល គឺមានសេចក្តីណែនាំមួយគឺតម្រូវឱ្យចុះបញ្ជី ប៉ុន្តែតើត្រូវញែក entity នេះយ៉ាងដូចម្តេច ប្រសិនបើ NGO គាត់ជានីតិបុគ្គល ហើយស្វ័យប្រវត្តិគឺគាត់នឹងអ្នកជាប់ពន្ធមធ្យម? មួយទៀតដោយសារតែគាត់ជាស្ថាប័នមួយដូចនេះគាត់ជាប់ជា Tax Entity មួយរួចជាស្រេចនៅក្នុងការបង់ពន្ធប្រាក់បៀវត្ស លនិងល ហើយអង្គការនេះដដែលគាត់បានទៅធ្វើ Business មួយទៀត ថាតើត្រូវបង្កើត Tax Entity ថ្មីឬយ៉ាងម៉េច? ហើយបង្កើតយ៉ាងដូចម្តេច?ដូច្នេះរាល់បញ្ហាទាំងអស់នេះគឺស្ថិតនៅការជជែកជាមួយផ្នែកពន្ធដារនៅឡើយ ដើម្បីស្វែងរកនូវដំណោះស្រាយ និងស្វែងរកនៅឯកសារ ក្របខណ្ឌគតិយុត្តិណាមួយដើម្បីឆ្លើយតបទៅតាមបញ្ហាអស់នេះ។ ជារួម ខ្ញុំគិតថា វាមិនមានផ្លូវផ្សេងក្រៅពីការ report ជា revenue នេះទេព្រោះវាជា revenue របស់អង្គភាព។

ចំពោះសំណួរទី ២ គឺត្រូវបំបែក PPE និង Investment Property ចេញពីគ្នានៅក្នុង statement of financial position ឬក៏ Balance Sheet

ចំពោះសំណួរ Going Concern, សូមបងពិនិត្យមើលនៅ Note to Financial Statement។ ជាធម្មតាខាងអង្គការគាត់រៀបចំរបាយការណ៍ផ្អែកទៅតាម Going Concern មានន័យថាគាត់អាច operate រយៈពេល ១២ខែទៅមុខ ប៉ុន្តែប្រសិនជាគាត់មិនច្បាស់ថាគាត់អាច operate បាន គាត់ត្រូវ Disclose នៅក្នុង Note to financial statement។ នៅក្នុង Note នេះគេនឹងបញ្ជាក់ថាអង្គភាពនឹងត្រូវ disclose របៀបដូចម្តេច ហើយ transaction នេះមានអ្វីខ្លះ? ហើយក៏មានការ estimate ថានឹងមានផលប៉ះពាល់ទៅ Asset ដូច ម្តេចខ្លះ?

### ការចូលរួមពី លោក រឿង ប៊ុនហេង ជាConsultant ពីស្ថាប័នបច្ចេកទេស

ខ្ញុំសូមអរគុណដល់ និយ័តករគណនេយ្យនិងសវនកម្ម ដែលបានបង្កើតជាស្តង់ដារបទដ្ឋានសម្រាប់អង្គការមិនមែនរដ្ឋាភិបាល។ ដោយសារតែកន្លងមកគឺយើងអនុវត្តដោយមិនមានបទដ្ឋានទេ ដោយយើងប្រើប្រាស់ Modify Cash Basis ដែល NGO ធ្វើការ Modify តាម policy មួយៗរបស់សាម៉ីអង្គការរៀងៗខ្លួនប៉ុន្តែឥលូវយើងមានស្តង់ដារកម្រិត១ និងកម្រិត២ ដែលជាមូលដ្ឋានស៊ីគ្នាមួយរវាងអង្គការមួយទៅអង្គការមួយអនវត្តប្រព័ន្ធព័ត៌មានស្តង់ដារគណនេយ្យតែមួយដូច្នេះយើងងាយស្រួលនៅក្នុងការប្រៀបធៀបព័ត៌មាន។ នៅក្នុងកំឡុងពេលដែលយើងរៀបចំស្តង់ដារនេះគឺយើងពិនិត្យមើលឃើញថា ៤ចំណុចដែលបានលើកឡើងនេះគឺសមរម្យដែលគួរតែពិចារណារ ហើយកន្លងមកគឺមិនមែនតែអង្គការទេសូម្បីស្ថាប័នឯកជន ត្រង់៤ចំណុចនេះគឺសុទ្ធតែជាការលំបាកនៅក្នុងការធ្វើការសម្រេចចិត្តកន្លងមក ដែលយើងបានប្រើ Subjective Judgement គឺជាការសម្រេច

ដោយការប៉ាន់ស្មាន់មួយទៅលើ៤ចំណុចនោះ ដោយខ្ញុំគិតថាវាគួរតែយើងពិនិត្យមើលដែរដើម្បីបន្សីជាមួយបរិបទខ្មែរយើងឥលូវនេះយើងមាន Transaction ជាច្រើន។ ហើយខ្ញុំគាំទ្រឱ្យមានការពិភាក្សាត្រង់ចំណុចទាំង៤ដែលយើងបានលើកឡើងនេះហើយសង្ឃឹមថាអ្នកស្រី បូនីនឹងពាំនាំពាក្យពេចន៍នេះទៅពិចារណាថាតើគួរតែគិតគូរលើធាតុចូលទាំង៤នេះឬក៏យ៉ាងណា។ ប្រសិនណាជាយើងកាត់បន្ថយគឺយើងនឹងកាត់បន្ថយបន្ទុកសម្រាប់ NGO កាត់បន្ថយការស្មុគស្មាញ គឺកាត់បន្ថយចំណាយមួយចំនួនសម្រាប់ NGO រួមទាំងសេវាសវនកម្ម សេវាគណនេយ្យជាដើម។ ដោយសារតែភាពស្មុគស្មាញនៃស្តង់ដារនេះ ទី១ នឹងធ្វើឱ្យសេវាថ្លៃជាងមុន ទី២គឺមានកិច្ចការមួយចំនួនគឺយើងត្រូវត្រលប់ថយក្រោយ ខ្ញុំឧទាហរណ៍ ឆ្នាំ ២០១៩ ២០២០ជាដើម យើងប្រើ Cash Basis ហើយនិង Modified Cash Basis ហើយប្រសិនជាយើងផ្លាស់ប្តូរមកប្រើ កម្រិត២នេះ គឺយើងត្រូវ convert តួរលេខ ៣ឆ្នាំថយក្រោយដើម្បីយើងបានតួរលេខ Comparative ឆ្នាំ២០២០ និង ២០១៩ ដោយវាជាការចំណាយពេលមួយសម្រាប់ NGO ដោយ NGO អាចនឹងអត់មានធនធាននៅក្នុងការធ្វើ នេះជាចំណុចទី១ យើងគួរពិចារណា។ ខ្ញុំពិតជាគាំទ្រ ឧទាហរណ៍ ស្តង់ដារកម្រិតទី២នេះត្រូវបានអនុម័ត ខ្ញុំគិតថាមុនពេលអនុម័តយើងគួរតែមានកិច្ចប្រជុំមួយរវាងនិយ័តករ និងពន្ធដារជាតំណាងដែលមានឥទ្ធិពលហើយអាចពិភាក្សាជាផ្លូវការជាមួយគ្នាហើយមានកំណត់ហេតុ ដោយអាចអនុញ្ញាតឱ្យ NGO មានការអនុវត្តស្របគ្នារវាងស្តង់ដារគណនេយ្យ និងពន្ធដារ ប្រសិនជាមានចំណុចណារដូចគ្នាគឺមានការធូរស្រាលក្នុងបន្ទុកទាំងសងខាង ដោយមិនចាំបាច់ធ្វើការ Adjustment ច្រើន។ ចំពោះលិខិតស្នើសុំនេះក៏ខ្ញុំសុំមានការសង្កត់ធ្ងន់បន្ថែមដែរទៅកាន់លោកស្រី បូនី គឺទាក់ទងទៅលើការប្រើប្រាស់ស្តង់ដារកម្រិត១ ដោយអង្គប្រជុំគួរធ្វើពិភាក្សាគ្នាដែរថាតើគួរពន្យារដល់ពេលណា? ហើយកំឡុងពេលពន្យាតើមានធ្វើសកម្មភាពអ្វី?។ ហើយចំពោះការពិន័យអន្តរការណ៍ខ្ញុំជឿជាក់ថាឯកឧត្តម ប៉ូ ថារិន លោកនឹងពិចារណាឡើងវិញហើយ ដាក់ការពិគ្រោះយោបល់ឡើងវិញ ដើម្បីពិនិត្យមើលថាកន្លែងណាខ្លះយើងអាចធ្វើបាននៅក្នុងឆ្នាំ ២០២១ កន្លែងណាខ្លះយើងអាចធ្វើបាននៅឆ្នាំ ២០២២ ហើយការពិន័យគួរតែធ្វើឡើងនៅក្នុងឆ្នាំណាសម្រាប់ចំណែកណានៃប្រកាស សម្រាប់ខ្ញុំគឺសុំធ្វើការគាំទ្រក្នុងចំណុចនេះក្នុងនាមជា Consultant ។ ហើយគឺខ្ញុំសុំឱ្យមានការបណ្តុះបណ្តាលបន្ថែម ដោយសារតែពឹងផ្អែកតែលើការធ្វើបទបង្ហាញ Presentation គឺនឹងនៅតែមានការពិបាក ហើយគួរតែមានការ train ជាលម្អិតសម្រាប់ Specific Group។ ហើយប្រសិនជាការប្រសើរខាងអង្គការមិនមែនរដ្ឋាភិបាលអាចស្នើសុំម្ចាស់ជំនួយមានកញ្ចប់ថវិការនៅក្នុងចូលរួមការបណ្តុះបណ្តាលនេះ ផងដែរគឺកាន់តែពន្លឿនការប្រតិបត្តិនេះបន្ថែមទៀត។ នេះជាការចូលរួមរបស់ខ្ញុំសូមអរគុណ។

**ការឆ្លើយតបពីលោកស្រី នាង បូនី អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម**

ចំពោះការប្រជុំចង្អៀតរវាង ខាង NGO ខាងនិយ័តករ និងខាងពន្ធដារ យើងនឹងធ្វើម្តងទៀតនៅពេលដែលអត្ថបទប្រកាសយើងធ្វើហើយ ដូច្នេះយើងគ្រោងធ្វើនៅត្រីមាសទី៣។ ខ្ញុំក៏សូមទទួលយកអនុសាសន៍ត្រង់ចំណុចផ្តល់ការបណ្តុះបណ្តាល ដោយសារតែ NGO មានចំនួនច្រើន ដូច្នេះអាជ្ញាធរធ្វើអត់អស់ទេ ត្រង់កន្លែងនេះ

យើងនឹងកត់ត្រាជាធាតុចូលបន្ថែមដើម្បីយើងដាក់ជូនថ្នាក់ដឹកនាំតើយើងរកវិធីណា ឬក៏មូលនិធិណាមួយធ្វើជាកម្មវិធីដូចលោកប៊ុនហេងបានលើកឡើង ដើម្បីពង្រឹងប្រសិទ្ធភាពដល់ការបណ្តុះបណ្តាល (Training to Trainer) ដល់ NGO ដែលមានចំនួនច្រើន។ តើចំពោះការស្នើសុំទាំង៤នេះ តើខាង NGO មានរៀបជារបាយការណ៍ដើម្បីដាក់ជូនទៅនិយ័តករឬក៏អត់ទាន់រៀបទេ?

**ការឆ្លើយតបពីលោក រី សុវណ្ណា ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិនៃអង្គការ គសក**

ខ្ញុំបានដាក់លិខិតទៅឯកឧត្តម ប៊ូ ថារិន ដែលមានសំណើរ និងអនុសាសន៍ដែលក្រុមការងារអង្គការសង្គមស៊ីវិលបានដាក់ជូន។ ប៉ុន្តែដោយសារតែបរិបទនៃការរាតត្បាតនៃជម្ងឺកូវីដនេះគឺធ្វើឱ្យការទៅការិយាល័យ មានការលំបាក ដូច្នេះខ្ញុំក៏បានរៀបចំជាលិខិតហើយដាក់ជា Scanned Signature ហើយបានផ្ញើរជូន NAC ដោយផ្ញើរតាមរយៈកញ្ញា គួយ សេរីវឌ្ឍនា ដោយខ្ញុំបានធ្វើការដោយផ្ទាល់តាំងពីដំបូងទាក់ទងទៅនឹងវត្តមានឯកឧត្តម ប៊ូ ថារិន ហើយក៏ដូចជាក្រុមការងារផ្សេងៗទៀតដើម្បីចូលរួមនៅអង្គសិក្ខាសាលានៅថ្ងៃនេះ។ នៅពេលដែលស្ថានភាពការរាតត្បាតនៃជម្ងឺកូវីដ មានភាពធូរស្បើយ អង្គការគសក និងរៀបចំលិខិតជាផ្លូវការដាក់ជូនទៅនិយ័តករ និងសវនកម្មដោយភ្ជាប់ជូននូវធាតុចូលសិក្ខាសាលាថ្ងៃនេះដែរ សូមអរគុណ។

**ការឆ្លើយតបពីលោកស្រី នាង បូនី អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម**

កន្លងមកវេទិកាដែលយើងផ្តល់ការបណ្តុះបណ្តាល គឺយើងចង់បាន Feedback ដើម្បីឱ្យNGO ទាំងអស់គាត់អាចអនុវត្តបាន ដូច្នេះរាល់ការផ្តល់យោបល់ ឬការសំណូមពរ CCC អាចបញ្ជូនទៅនិយ័តករ និងសវនកម្មដោយយើងនឹងមានលិខិតឆ្លើយតបជាផ្លូវការ។ ឆ្លៀតឱកាសនេះនាងខ្ញុំចង់សួរបញ្ជាក់ Traction Requirement, នៅក្នុងអត្ថបទស្តង់ដារគឺគេមានសរសេរ ២ជម្រើស។ ចំពោះចំណុចទី១ ប្រសិនបើ NGO គាត់បង្ហាញតែឆ្នាំបច្ចុប្បន្នទេ តែគាត់នៅតែត្រូវភ្ជាប់ជាមួយស្តង់ដារដែលគាត់បានអនុវត្តពីមុន មានន័យថាគាត់មិនចាំបាច់ធ្វើ Comparative Figure ទេ។ ឬក៏គាត់អាចជ្រើសរើសជម្រើសទី ២ ដែលធ្វើ Current Period ហើយបូកនឹង Comparative 3 ឆ្នាំ នេះជាការបំភ្លឺសម្រាប់ចំណុចទី៤។

ហើយត្រង់ចំណុចវាក្យស័ព្ទគឺយើងទទួលយក ដោយស្តង់ដារនេះគឺយើងសិក្សាពីប្រទេសគេដែរ New Zealand ដូច្នេះអត្ថបទគេសរសេររៀងលេងពាក្យដែលអាចឱ្យពិបាកយល់។ ដូច្នេះនៅកន្លែងនេះពួកខ្ញុំនឹងទទួលយកមតិយោបល់ ហើយយើងនឹងធ្វើការកែសម្រួលទៅតាមបរិទខ្មែរយើង។

ខ្ញុំសូមបកទៅសំណួរ Provision និង Impairment ថាតើចង់ស្នើសុំរបៀបម៉េច?

**ការឆ្លើយតបពីលោករី សុវណ្ណា ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិនៃអង្គការ គសក**

ដោយសារតែការកំណត់ការប៉ាន់ស្មាននៃកាតព្វកិច្ចមួយចំនួន ដែលអាចវាស់ស្ទង់ជាថវិកា យើងយល់ថាជាការបង្កើនបន្ទុកឬក៏មានភាពស្មុគស្មាញដល់ការអនុវត្តកាតព្វកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល។ តាមរយៈការពិគ្រោះយោបល់បច្ចេកទេសនានា យើងសង្កេតឃើញចំណុចសំខាន់ៗចំនួន២ ទី១ គឺអង្គការសង្គមស៊ីវិលរបស់យើងមិនធ្លាប់អនុវត្តនូវវិធីសាស្ត្រនៃការវាយតម្លៃ ឬមានមូលដ្ឋាននៅកនុងការកំណត់តម្លៃជាពិសេសការពិចារណាទៅលើតម្លៃឡើងចុះ ឬស្ថានភាពអតិផរណានានាទេ ហើយម្យ៉ាងដូចដែលយើងមានការជម្រាបពីខាងដើមអញ្ចឹង គឺអង្គការមិនមែនរដ្ឋាភិបាលនៅកម្ពុជាយើងគឺមិនធ្លាប់អនុវត្តនីតិវិធីប៉ាន់ស្មានតម្លៃនេះទេ។ ករណីទី២ គឺដូចលោក ឆាយ គង់ លោកបានជម្រាបគឺអង្គការនិងសមាគមគឺគាត់ទទួលជំនួយពីបរទេស មួយចំនួនធំគឺរស់អាស្រ័យដោយសារតែជំនួយ ដូច្នេះនៅពេលដែលគាត់ធ្វើ Proposal សុំជំនួយ គាត់មិនបានប៉ាន់ស្មានសមវិធានធននេះទេ ហើយការប៉ាន់ស្មានបែបនេះក៏មិនសូវមានភាពប្រាកដនិយមផង ដូច្នេះអង្គការសង្គមស៊ីវិលស្នើសុំឱ្យដក់ចេញនូវសមវិធានធននេះ ដោយផ្អែកទៅលើកត្តាខាងលើ។

**ការចូលរួមពីលោក យឿង សុធារ៉ា អ្នកប្រឹក្សាផ្នែកច្បាប់នៃអង្គការ គសក**

ប្រសិនជាលុបចោលឬដាក់ជាជម្រើស តើមួយណាវាប្រសើរជាង ដោយយើងមិនអាចស្មានដឹងថានិន្នាការរបស់អង្គការសង្គមស៊ីវិលនៅថ្ងៃមុខ នឹងក្លាយទៅជាយ៉ាងណាទេ ដោយអង្គការនេះអាចមានសហគ្រាសឬក៏មានការរកចំណូល ឬក៏មានជាលក្ខណៈកូនកាត់ ដូច្នេះត្រង់ចំណុចនេះអាចទៅជាជំរើសដើម្បីឱ្យគាត់អាចធ្វើរបាយការណ៍បាន។

**ការឆ្លើយតបពីលោកស្រី នាន បូនី អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម**

ដូចដែលយើងបានជជែកគ្នាពីដើម ដោយកម្រិត២ នេះគឺផ្អែកតាមមូលដ្ឋានបង្គរ ដោយយើងបានយល់ជានិយមន័យហើយថា យើងមិនកត់ត្រាការចេញចូលនៃសាច់ប្រាក់ទេ ប៉ុន្តែប្រសិនជាយើង earn ឬក៏ជាប់ obligation យើងត្រូវតែកត់ត្រាកន្លែងហ្នឹង។ កន្លែងនេះខ្ញុំមិនអាចជូនជាការសម្រេចដាច់ណាត់បានទេ ដូច្នេះនាងខ្ញុំនឹងរង់ចាំលិខិតផ្លូវការវិញ។ ហើយស្តង់ដារនេះគឺយើងសិក្សាមកពីប្រទេសជិតខាងដែរ ដូច្នេះខាងបច្ចេកទេសរបស់ខ្ញុំនឹងត្រលប់ទៅមើលវិញ តើយើងគួរតែកែរកន្លែងណា គួរតែដាក់ចេញ ឬក៏ដាក់ជាជម្រើស ដើម្បីកុំឱ្យខុសទៅហ្នឹង Concept មូលដ្ឋានគណនេយ្យបង្គរ។

**ការឆ្លើយតបពីលោករី សុវណ្ណា ប្រធានផ្នែកគោលនយោបាយ ច្បាប់ និងតស៊ូមតិនៃអង្គការ គសក**

ឆ្លៀតក្នុងឱកាសនេះខ្ញុំសូមបញ្ជាក់ថាអង្គការសង្គមស៊ីវិល ឯកភាពតាមប្រសាសន៍របស់លោកស្រី គឺយើងហ្នឹងដាក់លិខិតជាផ្លូវការដាក់ជូនទៅនិយ័តករគណនេយ្យនិងសវនកម្ម។ ហើយការសម្រេចយ៉ាងណា ទៅតាម

នីតិវិធី ខាងនិយ័តករនិងសវនកម្មគឺលោក នឹងជូនដំណឹងមកវិញ។ ហើយតាមការពិភាក្សាផ្នែកបច្ចេកទេសខាងអង្គការសង្គមស៊ីវិលនេះគឺយើងសម្រេចស្នើសុំឱ្យដកចេញ ពីបរិបទអង្គការមិនមែនរដ្ឋាភិបាល។ ហើយខ្ញុំក៏ឆ្លៀតឱកាសនេះជូនអង្គការសមាគមផ្សេងប្រសិនបើលោកមានការយល់ឃើញផ្ទុយពីការលើកឡើងពីមន្ត្រីបច្ចេកទេស។ ដូច្នេះខ្ញុំមានចំណុច ២ យើងនឹងដាក់លិខិតទៅ និយ័តករនិងសវនកម្មដោយពន្យល់ត្រង់ចំណុច សមវិធានធននេះ ហើយនឹងរង់ចាំលិខិតឆ្លើយតបពីនិយ័តករគណនេយ្យ និងសវនកម្មវិញ។

**ការចូលរួមពីលោក កែវ រស្មី**

ប្រសិនបើខ្ញុំអានទៅតាម General Provision នេះទៅគឺជាជម្រើសទេដោយមិនមែន Requirement។ ដូច្នេះខ្ញុំគិតថាមិនបាច់លុបទេប៉ុន្តែចាត់ទុកជាជម្រើស។

**ការឆ្លើយតបពីលោកស្រី នាង បូនី អគ្គនាយករងនៃ និយ័តករគណនេយ្យនិងសវនកម្ម**

ដូចដែលបានជម្រាប ស្តង់ដារគឺផ្អែកទៅតាមមូលដ្ឋានគណនេយ្យបង្គរ ដូច្នេះផ្អែក សមវិធានធន នេះគឺយើងផ្អែកទៅលើមូលដ្ឋាននេះដើម្បីកុំឱ្យប្រាសចាក គឺសូមឱ្យយើងមានការពិនិត្យទាំងអស់គ្នា ដោយនេះជាគោលបំណងនៃកិច្ចប្រជុំសិក្ខាសាលានៅថ្ងៃនេះគឺយើងចង់បានជា Feedback ដើម្បីអនុវត្តបាន ដូច្នេះត្រង់កន្លែងនេះគឺយើងធ្វើយ៉ាងណាគឺកុំឱ្យប្រាសចាកគោលការគណនេយ្យ។

**ការចូលរួមពី លោក រឿង ប៊ុនហេង ជាConsultant ពីស្ថាប័នបច្ចេកទេស**

ជាក់ស្តែងនៅក្នុងការអនុវត្តកន្លងមកគឺមានការស្មុគស្មាញ រាល់ Accrual Concept គឺគួរតែមានពាក្យ Provision នេះ។ ក៏ប៉ុន្តែខ្ញុំគិតថាដើម្បីបន្ធូរបន្ថយភាពស្មុគស្មាញ ទី១ យើងបានណែនាំ ផ្តល់យោបល់ឱ្យមានការធ្វើតាមបទដ្ឋានគណនេយ្យ បង្គរ មួយតង់ ដោយវាអាចជាការលំបាកសម្រាប់ខាង NGO ម្តងហើយ ដូច្នេះប្រសិនបើយើងបន្ថែម Provision មួយទៀត វាអាចហ្នឹងបន្តភាពស្មុគស្មាញ ដល់គណនេយ្យករក្នុងវិស័យ NGO បន្ថែមទៀត វាមានការស្មុគស្មាញ ដោយឧទាហរណ៍ថាយើងជួលអគារគេ ហើយបន្ទាប់ពីជួលយើងត្រូវជួសជុលអគារគេឱ្យដូចដើមវិញ ដូច្នេះតម្លៃប៉ាន់ស្មាននៃការជួសជុលនៅពេលនេះគឺត្រូវប៉ានស្មានជាឧទាហរណ៍ ៥ឆ្នាំទៅមុខ ហើយបើផ្អែកតាម Provision គឺយើងត្រូវតែ Recognize ផ្អែកនេះទៅ Provision នេះ ដែលអាចឈានទៅរកភាពស្មុគស្មាញសម្រាប់ NGO ដែរ ក្នុងខណៈដែល NGO មិនច្រើនទេដែលមាន Transaction ដែលតម្រូវឱ្យមាន Provision។ ដូច្នេះសម្រាប់ខ្ញុំផ្ទាល់ដើម្បីសម្រួលដល់ការអនុវត្តគឺខ្ញុំគាំទ្រនូវការដកចេញនៃ Provision នេះចេញពីស្តង់ដារ ឬក៏ Accounting Estimate មួយចំនួនដែលពាក់ព័ន្ធ ដូចជា Impairment, Assessment value of Asset, Fixed Asset ដែលយើងត្រូវធ្វើការប៉ាន់ស្មាន។

## ៥. បិទកម្មវិធី

**លោកស្រី កែន សុភាព ប្រធានផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាលនៃ Heinrich Böll Stiftung និងសមាជិកក្រុមការងារហិរញ្ញវត្ថុនៃអង្គការគសក**

នាងខ្ញុំមានសេចក្តីសោមនស្សនៅក្នុងការបិទកម្មវិធីសិក្ខាសាលានៅថ្ងៃនេះ។ នៅក្នុងសិក្ខាសាលាពិគ្រោះយោបល់និងវេទិការៀនសូត្រពីចម្ងាយក្នុងប្រធានបទ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២។ ខ្ញុំឃើញថាជាផ្នែកមួយល្អ ដែលយើងទទួលបានអនុសាសន៍ ពីខាងអង្គការសង្គមស៊ីវិលមួយចំនួន ហើយខាងក្រុមការងារ គ.ស.ក គាត់បានរៀបចំអនុសាសន៍ចំនួន៤ដូចដែលលោក ឆាយ គង់បានធ្វើបទបង្ហាញ ហើយខាងអង្គការគ.ស.កនឹងរៀបចំធ្វើលិខិតអអនុសាសន៍ទាំង៤ចំណុចនេះដាក់ជូនឯកឧត្តម ប៊ូ ថារិន ដើម្បីពិចារណានៅធាតុចូលទៅលើ ស្តង់ដារបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញកម្រិត ២។ខ្ញុំសង្ឃឹមថាក្រុមការងារខាងនិយ័តករគណនេយ្យ និងសវនកម្ម នឹងធ្វើការពិចារណាទៅលើអនុសាសន៍នេះ។ នាងខ្ញុំក៏សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះលោកស្រី នាង បូនី ដែលជា អគ្គនាយករងនៃនិយ័តករគណនេយ្យនិងសវនកម្ម ដែលតំណាងឱ្យឯកឧត្តម ប៊ូ ថារិន ព្រមទាំងក្រុមការងារកញ្ញា គួយ សេរីវឌ្ឍនា មន្ត្រីបច្ចេកទេសនៃនិយ័តករគណនេយ្យនិងសវនកម្ម ដែលបានធ្វើបទបង្ហាញទៅលើចំណុចសំខាន់ៗ ដែលមាននៅក្នុងស្តង់ដារកម្រិត ២នេះ។ នាងខ្ញុំតំណាងឱ្យអង្គការគ.ស.ក នាងខ្ញុំសូមអរគុណជាថ្មីដល់វាគ្មិនកិត្តិយសក្រុមការងារអង្គការគ.ស.ក ព្រមទាំងអ្នកចូលរួមនៃអង្គការមិនមែនរដ្ឋាភិបាលទាំងអស់ដែលបានចូលរួមនៅក្នុងសិក្ខាសាលានៅថ្ងៃនេះ។ សូមអរគុណ! សូមបិទកម្មវិធី។

## ៦. លទ្ធផលវាយតម្លៃវគ្គសិក្សារៀនសូត្រ

បន្ទាប់ពីបញ្ចប់វេទិកាសិក្សារៀនសូត្រស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុលើកទី២៨ លោក សុខ ណេង អ្នកឯកទេសផ្នែកឧបករណ៍មិនបង្កទំនាស់បានស្នើឲ្យសិក្ខាកាមដែលបានចូលរួមបំពេញទម្រង់វាយតំលៃទៅលើវេទិកាសិក្សារៀនសូត្រទាំងមូលតាមរយៈប្រព័ន្ធអនឡាញ(Google Form)។ ខាងក្រោមគឺជាលទ្ធផលលម្អិតនៃការវាយតម្លៃរបស់សិក្ខាកាមទាំងមូលចំនួន ៤០នាក់ ក្នុងចំណោមសិក្ខាកាមសរុប ១៣៩ នាក់។

## ៥.១.ចំណុចទូទៅនៃវេទិកាសិក្សារៀនសូត្រ

តាមក្រាហ្វិកខាងស្តាំបង្ហាញថា សិក្ខាកាមពេញចិត្តខ្លាំងចំពោះវេទិកានេះ ព្រោះសិក្ខាកាមបានដាក់ពិន្ទុ ៨០% កំរិតលេខ៣ និង១០%កំរិតលេខ៤ ប៉ុន្តែក៏មាន១០%នៃសិក្ខាកាមបានដាក់ ១០%នៅកំរិតលេខ២ដែរ។ អ្នករៀបចំវេទិការៀនសូត្រនឹងតាមដានលើចំណុចលម្អិតនៃ១០%នេះហើយនឹងកែរលម្អវេទិការៀនសូត្រលើកក្រោយទៀត។




តាមតារាងទី១ខាងក្រោមបង្ហាញថា សិក្ខាកាមភាគច្រើនបានយល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធអនឡាញដែលបានទទួល ៦០% និង៣៨%នៅកំរិតលេខ៣និងលេខ៤ តែក៏មាន៣%នៃសិក្ខាកាមដាក់នៅកំរិតលេខ១ដែលបញ្ជាក់ថាមិនទានចេះប្រើប្រព័ន្ធ Google Meet ដូចនេះអ្នករៀបចំវេទិការៀនសូត្រនឹងបញ្ជ្រៀបអំពីការប្រើប្រាសប្រព័ន្ធGoogle Meet មុននិងកំឡុងពេលឲ្យបានច្រើនដង។ សិក្ខាកាមបង្ហាញថា ប្រធានបទនេះទាក់ទងនឹងការងាររបស់គាត់ ដែលគាត់បានដាក់ពិន្ទុ ៤៥%កំរិតលេខ៣ និង ៤៨%នៅកំរិតលេខ៤ និងគោលបំណងវេទិកាត្រូវបានបំពេញ៥៨%កំរិតលេខ៣ និង១៣%កំរិតលេខ៤ ប៉ុន្តែ៥% និង២៥% នៃសិក្ខាកាមបានដាក់នៅកំរិតលេខ១ និងលេខ២ដែលគិតថាមិនពេញចិត្តពីសិក្ខាកាមព្រោះរបាយការណ៍ស្តង់ដារហិរញ្ញវត្ថុកម្ពុជាកំរិតទី២មិនទាន់ជាទំរងរបាយការណ៍ដែលនឹងដាក់ឲ្យប្រើប្រាសទេ។ លើសពីនេះទៀត វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ ៧០% និង១៥ ក្នុងកំរិតលេខ៣ និងលេខ៤ បង្ហាញថាសិក្ខាកាមពេញចិត្តខ្លាំង។ សូមអានលម្អិតក្នុងតារាងខាងក្រោម៖

| **តើអ្នកយល់យ៉ាងដូម្តេចចំពោះចំណុចខាងក្រោម?សូមដាក់ពិន្ទុពី ១ ដល់ 4**<br>១ = មិនពេញចិត្តសោះ ៤ = ពេញចិត្តខ្លាំង | ១<br>% | ២<br>% | ៣<br>% | ៤<br>% | សរុប<br>% | ពិន្ទុមធ្យម |
|---|---|---|---|---|---|---|
| ១.ការលើកទឹកចិត្តឲ្យសួរសំណួរ និងទំនាក់ទំនងតាមប្រអប់សារ | 0 | 0 | ៦៥ | ៣៥ | ១០០ | ៣ |
| ២.ប្រធានបទនេះទាក់ទងនឹងការងាររបស់ខ្ញុំ | 0 | ៨ | ៤៥ | ៤៨ | ១០០ | ៣ |
| ៣.មាតិកាត្រូវបានរៀបចំយ៉ាងល្អ ហើយងាយយល់ | ៥ | ១៨ | ៧៣ | ៥ | ១០០ | ៣ |
| ៤.ឯកសារដែលបានផ្តល់ឲ្យមានសារៈប្រយោជន៍មែនទែន | ៥ | ១៨ | ៥៣ | ២៥ | ១០០ | ៣ |
| ៥.វាគ្មិន/អ្នកសម្របសម្រួលមានចំណេះដឹងអំពីប្រធានបទក្នុងវេទិកានេះ | 0 | ១៥ | ៧០ | ១៥ | ១០០ | ២ |
| ៦.វាគ្មិន/អ្នកសម្របសម្រួលមានការត្រៀមរៀបចំយ៉ាងល្អ | 0 | ១៨ | ៧៥ | ៨ | ១០០ | ៣ |

| | | | | | | |
|---|---|---|---|---|---|---|
| ៧.គោលបំណងវេទិកាត្រូវបានបំពេញ | ៥ | ២៥ | ៥៨ | ១៣ | ១០០ | ៣ |
| ៨.ការបែងចែកពេលវេលាសម្រាប់វេទិកាមានរយៈពេលគ្រប់គ្រាន់ | ០ | ១៣ | ៥៥ | ៣៣ | ១០០ | ៣ |
| ៩.យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធអនឡាញ(Google Meet) សម្រាប់វេទិការៀនសូត្រ | ៣ | ០ | ៦០ | ៣៨ | ១០០ | ៣ |
| ពិន្ទុមធ្យមសរុប | | | | | | ២៧ |

## ៧. ឧបសម្ព័ន្ធ

១. របៀបវារៈ

| ម៉ោង (ថ្ងៃរសៀល) | ប្រធានបទ | អ្នកសម្របសម្រួល |
|---|---|---|
| ០១:៣០–០២:០០ | - ចុះឈ្មោះចូល និងស្វាគមន៍សិក្ខាកាម<br>- ណែនាំអំពីការប្រើប្រាស់Google Meet និងគោលបំណង | **លោក សុខ ណេង**<br>អ្នកឯកទេសផ្នែកDNH |
| ០២:០០–០២:៣០ | - ចំណាប់អារម្មណ៍ និងស្វាគមន៍<br>បើកកម្មវិធី | **លោកស្រី ស៊ិន ពុទ្ធារី**<br>នាយិកាប្រតិបត្តិអង្គការ គសក<br>**លោកស្រី នាង បូនី** តំណាងឯកឧត្តម **ប៊ូ ថារិន** អគ្គនាយកនៃនិយ័តករគណនេយ្យ និងសវនកម្ម(ន.គ.ស) |
| ០២:៣០–០២:៥០ | - បទបង្ហាញស្ដីពីធាតុ និងអនុសាសន៍លើស្តង់ដាររបាយការណ៍កម្ពុជាកំរិតទី២របស់អង្គការសង្គមស៊ីវិល | **លោក ឆាយ គង់**<br>ប្រធានផ្នែកហិរញ្ញវត្ថុ នៃអង្គការ iDE<br>គាំទ្រដោយ **លោក យឿន សុធារ៉ា** ទីប្រឹក្សាផ្នែកច្បាប់ |
| ០២:៥០-០៤:១៥ | បទបង្ហាញបច្ចេកទេសស្តងដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាកំរិតទី ២<br>- ស្តត់ដាររបាយការណ៍ហិរញ្ញវត្ថុ និងគោលបំណងប្រើប្រាស for NFPEs (Tier 2)<br>- សំណួរ និងចំលើយ | **សម្របសម្រួលដោយលោកយឿន សុធារ៉ា** ទីប្រឹក្សាផ្នែកច្បាប់<br>**កញ្ញា គួយ សេរីវឌ្ឍនា** |

| | | | |
|---|---|---|---|
| | | | មន្ត្រីបច្ចេកទេសនៃនិយ័តករគណនេយ្យ និងសវនកម្ម |
| ០៤:១៥-០៤:៣០ | - | បិទកម្មវិធី | **លោកស្រី កែន សុភាព** ប្រធានផ្នែកហិរញ្ញវត្ថុនិងរដ្ឋបាលនៃ Heinrich Böll Stiftung និងសមាជិកក្រុមការងារ ហិរញ្ញវត្ថុនៃអង្គការគសក |
| ០៤:៣០ | - | ចុងបញ្ចប់នៃកម្មវិធី | |


#9-11, Street. 476,
Toul Tompoung1, Chamkamorn
P.O. Box 885, Phnom Penh, Cambodia

២. រូបថតវេទិការៀនសូត្រ

